ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះ "តំបន់ប្រាសាទសំបូរព្រៃគុក" ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនសាធារណជន និងប្រជាជនកម្ពុជាទាំងអស់មេត្តាជ្រាបថា នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំលើកទី៤១ នៅទីក្រុង Krakow ប្រទេសប៉ូឡូញ គណៈកម្មការបេតិកភណ្ឌពិភពលោក បានពិនិត្យ ពិភាក្សា និងវាយតម្លៃថា "**តំបន់ប្រាសាទសំបូរព្រៃគុក**" មានគុណតម្លៃលេចធ្លោជាសកល ហើយតាមរយៈ **DECISION 41 COM 8B.15** បានសម្រេចចុះ "**តំបន់ប្រាសាទសំបូរព្រៃគុក**" ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ការសម្រេចនៃគណៈកម្មការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូនេះ គឺជាមោទនភាពជាតិដ៏ធំធេងថ្មីមួយទៀត ដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំប្រកបដោយគតិបណ្ឌិត តែងតែយកចិត្តទុកដាក់លើកកិត្តិយសជាតិនៅលើឆាកអន្តរជាតិ ក៏ដូចជាឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រង ការងារ អភិរក្ស និងអភិវឌ្ឍន៍ បេតិកភណ្ឌប្រកបដោយចីរភាព។

**ការថែរក្សា និងការពារបេតិកភណ្ឌជាតិ គឺជាភារកិច្ចរបស់កូនខ្មែរគ្រប់ៗរូប ។**

ភ្នំពេញ, ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៧

ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ